ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

ក្រសួងពាណិជ្ជកម្ម
**Ministry of Commerce**

ភ្នំពេញ, ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៧

# សេចក្តីជូនដំណឹង

កាលពីព្រឹកថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ មានលេខទូរស័ព្ទចំនួន បីខ្សែ ៖ **០៩៦ ៥៥២ ០៩០៩**, **០៩២ ២៤៩ ៣៣៣** និង **០១២ ៨៤០ ១២៨** បានទូរស័ព្ទទៅ លោកប្រធានមន្ទីរ អនុប្រធានមន្ទីរ និង ប្រធានការិយាល័យ នៅមន្ទីរពាណិជ្ជកម្មខេត្តតាកែវ ដោយប្រាប់ថា ជាជំនួយការឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងម្នាក់ទៀតជាអនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ ដោយប្រាប់ឲ្យមន្ត្រីរៀបចំធ្វើបែបបទឡើងកាំប្រាក់ ជូនមន្ត្រីរាជការនៅមន្ទីរពាណិជ្ជកម្មខេត្តតាកែវ ។

ពាក់ព័ន្ធនឹងករណីខាងលើនេះ ក្រសួងពាណិជ្ជកម្ម សូមជម្រាបជូន **ឯកឧត្តម លោក លោកស្រី មន្ត្រីរាជការក្រោមឱវាទក្រសួងពាណិជ្ជកម្ម** ជ្រាបថា៖ ព័ត៌មានខាងលើនេះ ជាព័ត៌មានមិនពិត គឺជាការឆបោកដើម្បីផលប្រយោជន៍របស់ជនខិលខូចនោះប៉ុណ្ណោះទេ ពីព្រោះការដំឡើងកាំប្រាក់ក្រសួងបានរៀបចំរួចហើយ។ ករណីបែបនេះ ធ្លាប់បានកើតឡើងម្តងរួចមកហើយ កាលពីព្រឹកថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ គឺមានជនឆបោកបានទូរស័ព្ទទៅលោកប្រធានមន្ទីរ និងមន្ត្រីមន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង ដោយប្រាប់ថា ជាជំនួយការឯកឧត្តម **ឈួន ដារ៉ា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងប្រាប់ឲ្យមន្ត្រីវេលុយទៅជាបន្ទាន់ចំនួន ៣០០ដុល្លារ ដើម្បីរត់ការរឿងដំឡើងកាំប្រាក់ ។

អាស្រ័យហេតុនេះ ក្រសួង សូមជូនដំណឹងដល់ **ឯកឧត្តម លោក លោកស្រី មន្ត្រីរាជការក្រោមឱវាទក្រសួងពាណិជ្ជកម្ម** មេត្តាប្រុងប្រយ័ត្នទាក់ទងនឹងករណីឆបោកខាងលើ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោក លោកស្រី មន្ត្រីរាជការក្រោមឱវាទក្រសួងពាណិជ្ជកម្មទាំងអស់** ជ្រាបជាព័ត៌មាន ។

សូមអរគុណ !

ក្រសួងពាណិជ្ជកម្ម

<u>បញ្ជាក់៖</u>
ករណីមានរឿងដូចខាងលើ
សូមទំនាក់ទំនងមកនាយកដ្ឋានបុគ្គលិក
ទូរស័ព្ទលេខ៖ ០៧៧ ៩៨៩ ៨៩៧ / ០១២ ៦៤៤ ២៩៩

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
*Phone/Facsimile: (855)-23 866 469*